**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**
លេខៈ ៨៨ អនក្រ.បក

# អនុក្រឹត្យ
## ស្ដីពី
## ការប្រែក្លាយសាលាគូមិន្ទនគរបាល
## ទៅជាបណ្ឌិត្យសភានគរបាលកម្ពុជា

...

**រាជរដ្ឋាភិបាល**

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៧០៤/១២៤ ចុះថ្ងៃទី១៥ ខែកក្កដា ឆ្នាំ២០០៤ ស្ដីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្ដីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០១ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ ស្ដីពីការបង្កើតក្រសួងអប់រំ យុវជន និងកីឡា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៨ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ ស្ដីពីការបង្កើតក្រសួងមហាផ្ទៃ
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៣០៣/១២៩ ចុះថ្ងៃទី ៣១ ខែ មីនា ឆ្នាំ ២០០៣ ស្ដីពីការទទួលស្គាល់គុណភាពអប់រំឧត្ដមសិក្សា
- បានឃើញអនុក្រឹត្យលេខ ២១ អនក្រ.បក ចុះថ្ងៃទី ២៣ ខែ មីនា ឆ្នាំ ១៩៩៨ ស្ដីពីការរៀបចំ និងការប្រព្រឹត្តទៅ របស់ក្រសួងអប់រំ យុវជន និងកីឡា
- បានឃើញអនុក្រឹត្យលេខ ១៦ អនក្រ ចុះថ្ងៃទី ២០ ខែ ធ្នូ ឆ្នាំ ១៩៩៣ ស្ដីពីការរៀបចំ និងការប្រព្រឹត្តទៅ របស់ក្រសួងមហាផ្ទៃ
- បានឃើញអនុក្រឹត្យលេខ ០១ អនក្រ. ចុះថ្ងៃទី ២០ ខែ មករា ឆ្នាំ ១៩៩២ ស្ដីពីការបង្កើត និងការគ្រប់គ្រងគ្រឹះស្ថានឧត្ដមសិក្សា និងសិក្សាឯកទេស
- បានឃើញអនុក្រឹត្យលេខ ៥៤ អនក្រ.បក ចុះថ្ងៃទី ១៣ ខែ មិថុនា ឆ្នាំ ២០០២ ស្ដីពីលក្ខណវិនិច្ឆ័យនៃការបង្កើតសាកលវិទ្យាល័យ

- បានឃើញអនុក្រឹត្យលេខ ៣៧ អនក្រ.បក ចុះថ្ងៃទី ០២ ខែ ឧសភា ឆ្នាំ ២០០២ ស្តីពីការបង្កើតសាលាភូមិន្ទនគរបាល
- បានទទួលការឯកភាពពីគណៈរដ្ឋមន្ត្រី ក្នុងសម័យប្រជុំពេញអង្គ នាថ្ងៃទី១៣ ខែកក្កដា ឆ្នាំ២០០៧

**ស ម្រេ ច**

**មាត្រា ១ .-**

ត្រូវបានប្រែក្លាយសាលាភូមិន្ទនគរបាល ទៅជា**បណ្ឌិត្យសភានគរបាលកម្ពុជា** សរសេរកាត់ " ប.ន.ក ជាភាសាអង់គ្លេស " Police Academy of Cambodia" សរសេរកាត់ " P.A.C " ។ បណ្ឌិត្យសភានគរបាលកម្ពុជ មានទីតាំងនៅក្នុង ភូមិ ស្លាកែន្លង ឃុំ ដីឥដ្ឋ ស្រុក កៀនស្វាយ ខេត្ត កណ្តាល ។

**មាត្រា ២ .-**

បណ្ឌិត្យសភានគរបាលកម្ពុជាមានឋានៈស្មើអគ្គនាយកដ្ឋាន និង ស្ថិតនៅក្រោមការគ្រប់គ្រងរបស់ ក្រសួងមហាផ្ទៃ ។ បណ្ឌិត្យសភានគរបាលកម្ពុជា ដឹកនាំដោយប្រធានមួយរូប និង អនុប្រធានមួយចំនួន ជាជំនួយកា តាមការចាំបាច់ ។

**មាត្រា ៣ .-**

បណ្ឌិត្យសភានគរបាលកម្ពុជា មានតួនាទីជាគ្រឹះស្ថានសិក្សាស្រាវជ្រាវវិទ្យាសាស្ត្រពាក់ព័ន្ធដល់កិច្ចការ សន្តិសុខ សណ្តាប់ធ្នាប់សាធារណៈ និង ធ្វើការបណ្តុះបណ្តាលធនធានមនុស្ស លើវិស័យសន្តិសុខ សណ្តាប់ធ្នាប់ សាធារណៈ ចំណេះដឹងទូទៅ និង ភាសាបរទេស ជូនដល់កងកម្លាំងនគរបាល គ្រប់លំដាប់ថ្នាក់ សិស្ស និស្សិត និងមន្ត្រីរាជការ ដែលមានការពាក់ព័ន្ធ លើវិស័យសន្តិសុខ សណ្តាប់ធ្នាប់សាធារណៈ ។

**មាត្រា ៤ .-**

បណ្ឌិត្យសភានគរបាលកម្ពុជាមានភារកិច្ចជាអាទិ៍ដូចតទៅ ៖

- ធ្វើការស្រាវជ្រាវវិទ្យាសាស្ត្រ ពាក់ព័ន្ធដល់កិច្ចការសន្តិសុខ សណ្តាប់ធ្នាប់សាធារណៈ
- រៀបចំផែនការបណ្តុះបណ្តាលកងកម្លាំងនគរបាលជាតិ កម្រិតបរិញ្ញាបត្ររង បរិញ្ញាបត្រ បរិញ្ញាបត្រ ជាន់ខ្ពស់ និងបណ្ឌិត
- រៀបចំផែនការ និង កម្មវិធីវិក្រឹតការ សុក្រឹតការ ដល់នាយនគរបាល នាយនគរបាលជាន់ខ្ពស់ នាយនគរបាល ថ្នាក់ឧត្តមសេនីយ៍ ឱ្យបានស៊ីជម្រៅលើមុខជំនាញឯកទេស និង វិធីសាស្ត្រថ្មីៗ នៃកង កម្លាំងនគរបាលជាតិ ស្របតាមសភាពការណ៍សន្តិសុខ សណ្តាប់ធ្នាប់សង្គម និង ការអភិវឌ្ឍរបស់ ប្រទេសជាតិ
- រៀបចំគម្រោងផែនការថវិកា សម្រាប់ការងារបណ្តុះបណ្តាលកងកម្លាំងនគរបាលជាតិ និងកិច្ចដំណើរ ការរបស់បណ្ឌិត្យសភានគរបាលកម្ពុជា ។ គ្រប់គ្រងចំណូល និងបញ្ជាចំណាយ សមស្របតាមនីតិវិធី ហិរញ្ញវត្ថុ និងតាមគម្រោងផែនការថវិកាប្រចាំឆ្នាំ

-សិក្សាស្រាវជ្រាវ ធ្វើទំនើបភាវូបនីយកម្មខ្លឹមសារឯកសារបង្ហាត់បង្រៀន កម្មវិធីសិក្សា និងកម្មសិក្ស
ប្រតិបត្តិ
-គ្រប់គ្រងមន្ត្រីនគរបាលក្រោមឱវាទ និងធ្វើការវាយតម្លៃមន្ត្រីនគរបាលក្រោមឱវាទ ដើម្បីស្នើសុំតែ
តាំងមុខតំណែង ផ្ទេរភារកិច្ច ដំឡើងឋានន្តរសក្តិឬដាក់វិន័យជូនថ្នាក់ដឹកនាំក្រសួងពិនិត្យ និង សម្រេ
-ធ្វើរបាយការណ៍ តាមការកំណត់ ជូនក្រសួងមហាផ្ទៃ
-ទទួលអនុវត្តភារកិច្ចផ្សេងៗទៀត ដែលរដ្ឋមន្ត្រីក្រសួងមហាផ្ទៃប្រគល់ឱ្យ ។

**មាត្រា ៥ .-**

បណ្ឌិត្យសភានគរបាលកម្ពុជា ធ្វើការបណ្តុះបណ្តាល កម្រិតបរិញ្ញាបត្ររង បរិញ្ញាបត្រ បរិញ្ញាបត្រជាន់ខ្ពស់ និង បណ្ឌិត ។ បណ្ឌិត្យសភានគរបាលកម្ពុជា ត្រូវរៀបចំកម្មវិធីសិក្សាគ្រប់កម្រិត និង គ្រប់មុខជំនាញ ដោយមានការឯកភាពពីក្រសួងមហាផ្ទៃ និង មានការទទួលស្គាល់ពីក្រសួងអប់រំ យុវជន និងកីឡា ។

**មាត្រា ៦ .-**

បណ្ឌិត្យសភានគរបាលកម្ពុជា មានមន្ទីរចាត់ការ ១ (មួយ) និងវិទ្យាស្ថាន ចំនួន ៤ (បួន) ÷

១. មន្ទីរចាត់ការ

២. វិទ្យាស្ថានស្រាវជ្រាវវិទ្យាសាស្ត្រនគរបាល

៣. វិទ្យាស្ថានបណ្តុះបណ្តាលវិជ្ជាជីវៈនគរបាល

៤. វិទ្យាស្ថានគ្រប់គ្រង និងបញ្ជាដឹកនាំ

៥. វិទ្យាស្ថានព័ត៌មានវិទ្យា និងភាសាបរទេស

ប្រធានមន្ទីរចាត់ការ នាយកវិទ្យាស្ថាន មានឋានៈស្មើប្រធាននាយកដ្ឋាន ។ ទៅថ្ងៃអនាគត យោងតាមសេចក្តីត្រូវការចាំបាច់របស់ក្រសួងមហាផ្ទៃ បណ្ឌិត្យសភានគរបាលកម្ពុជា អាចបើកសាខា មន្ទីរ វិទ្យាស្ថាន ឬ មុខជំនាញដទៃទៀត ដោយអនុលោមទៅតាមមាត្រា៥ នៃអនុក្រឹត្យនេះ ។

**មាត្រា ៧ .-**

លក្ខខណ្ឌជ្រើសរើសសិស្ស-និស្សិតឱ្យចូលសិក្សា នៅបណ្ឌិត្យសភានគរបាលកម្ពុជា ត្រូវកំណត់ដោយប្រកាសរបស់ក្រសួងមហាផ្ទៃ ដោយសម្របសម្រួលទៅតាមបទដ្ឋាន របស់ក្រសួងអប់រំ យុវជន និងកីឡា ស្តីពីការកំណត់លក្ខខណ្ឌនៃការចូលរៀននៅឧត្តមសិក្សា និង ការណែនាំពីគណៈកម្មាធិការទទួលស្គាល់គុណភាពអប់រំនៃកម្ពុជា ។

**មាត្រា ៨ .-**

និស្សិត ដែលបានរៀនចប់កម្មវិធីសិក្សារបស់បណ្ឌិត្យសភានគរបាលកម្ពុជា និង ទទួលបានជោគជ័យក្នុងការប្រឡងបញ្ចប់ការសិក្សា ត្រូវទទួលសញ្ញាបត្រតាមកម្រិត និង តាមមុខជំនាញ ដែលបានសិក្សា ។

សញ្ញាបត្រនេះ នឹងចុះហត្ថលេខាដោយ ប្រធានបណ្ឌិត្យសភានគរបាលកម្ពុជា និងរដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និងរដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា ។

**មាត្រា ៩ .–**

ក្រសួងមហាផ្ទៃ និង ក្រសួងអប់រំ យុវជន និងកីឡា ត្រូវសហការរៀបចំកម្មវិធីសិក្សា និង ជ្រើសរើ សាស្ត្រាចារ្យមកបង្រៀន នៅបណ្ឌិត្យសភានគរបាលកម្ពុជា តាមតម្រូវការ និង ភារកិច្ចកសាងធនធានមនុស្សពេ វិស័យសន្តិសុខ សណ្តាប់ធ្នាប់សាធារណៈ ។

**មាត្រា ១០ .–**

ការរៀបចំរចនាសម្ព័ន្ធ តួនាទី ភារកិច្ចរបស់អង្គភាពចំណុះ និង ការប្រព្រឹត្តទៅ របស់បណ្ឌិត្យសភ នគរបាលកម្ពុជា ត្រូវកំណត់ដោយប្រកាសរបស់ក្រសួងមហាផ្ទៃ ។

**មាត្រា ១១ .–**

បទប្បញ្ញត្តិទាំងឡាយណា ដែលផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍ ។

**មាត្រា ១២ .–**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួ មហាផ្ទៃ រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា រដ្ឋមន្ត្រី រដ្ឋលេខាធិការគ្រប់ក្រសួង ស្ថាប័នពាក់ព័ន្ធ អគ្គស្នងកា នគរបាលជាតិ និង ប្រធានបណ្ឌិត្យសភានគរបាលកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ ចាប់ពីថ្ងៃចុះហត្ថលេខ តទៅ ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ២៧ ខែ កក្កដា ឆ្នាំ ២០០៧

នាយករដ្ឋមន្ត្រី

ហ៊ុន សែន

កន្លែងទទួល

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឯកឧត្តមឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា ១២
- រាជកិច្ច
- ឯកសារ .កាលប្បវត្តិ